# ឬកពាជនពាល

## បទពាក្យ៨

ព្រះពុទ្ធទ្រង់ត្រាស់ច្បាស់ឥតលៀមលាក់ លើកឡើងបញ្ជាក់កិរិយាពាលោ
គំនិតលីបអើតកំណើតជាប់មោហ៍ សាងបាបហៀវហូរឥតមានអៀនខ្មាស់ ។
ឫកពាជនពាលមានបីក្រារ ញាតិគ្រប់កាយាចងចាំអោយច្បាស់
ពាលពិតសាមាន្យមានក្មេងមានចាស់ ល្ងង់ខ្លះចេះខ្លះចំរុះរូបា ។
មួយនឹងគិតអ្វីគិតតែអាក្រក់ គិតប៉ងលួចឆក់កាប់ចាក់ប្រហារ
គិតល្បិចកិច្ចកលផ្ទាញ់ផ្ទាលលោកា គិតកេងកិច្ចការប្រាថ្នាទ្រព្យា ។
គិតរាគិតរាំងពាំងផ្លូវអ្នកផង គិតប៉ុនគិតប៉ងចងកម្មវេរា
គិតអោយគេទុក្ខខ្លួនសុខរមនា គិតខុសធម្មាវៀរកម្មបវរ ។
ពីរនឹងធ្វើអ្វីធ្វើតែទុច្ចរិត ធ្វើខុសក្រមក្រឹត្យឃ្លាតច្បាប់ព្រះធម៌
ច្រងេងច្រងាងឡើងចាងឡើង ក មិនគិតខ្មៅសអំណរតែទុក្ខ ។
ប្រព្រឹត្តឈ្លានពានគ្មានក្តីអៀនខ្មាស់ សាងកម្មផ្តេសផ្តាស់មិនមើលក្រោយមុខ
កម្មមិនចំរើនក្រវើនរាវរុក ពារខ្មោះពារគុកមុខខ្លាញ់ងងើល ។
បីនឹងចរចាហាមាត់ស្រដី ពោលតែអប្រិយសំដីពព្រើល
ចាក់ដោតញុះញង់បង្អាប់បង្អើល វាសវាតអោយមើលឃើញតែទុច្ចរិត ។
កុហកភូតភរបញ្ជោរនាយអាយ អ្នកស្តាប់សប្បាយភ្លេចខ្លួនភ្លេចគិត
ជ្រើសរើសយករឿងដែលខំប្រឌិត មកធ្វើរឿងពិតអោយគេជឿបាន ។
ទាំងបីនេះហើយជាឫកជនពាល ព្រះពុទ្ធតិះដៀលថាផ្លូវសាមាន្យ
បើជនណាចៀសនឹងសុខក្សេមក្សាន្ត គ្មានទុករំខាននៅក្នុងសង្សារ ។
បើយកបីនេះមកដាក់ក្នុងកាយ នឹងមានអន្តរាយព្រោះកាយវាចា
ចិត្តគិតអប្រិយកាយសាងឫស្យា មាត់ប្រឹងចរចាប្រហារខ្លួនឯង ។

Ca. ២០ ឧសភា ២០០៦

ភិក្ខុ ស្វាត សាលឿម